# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ គួរធ្វើបុណ្យរំលឹករាល់ឆ្នាំចំពោះព្រះសង្ឃដែលត្រូវអ្នកនយោបាយធ្វើគត់ ។

website ៖ www.hoksavann.org

*ថ្ងៃទី១៨ កក្កដា ២០០៩*



តាមអ្នកជំនាញការថា ក្នុងចំណោមជនជាតិខ្មែរចំនួន១លាន៧សែននាក់ ដែលបានស្លាប់នៅក្នុងសម័យវាលពិឃាតរបស់ខ្មែរក្រហម ព្រះសង្ឃក៏ត្រូវសុគតគួររន្ធត់ជាច្រើនពាន់អង្គ ។ ដោយមនោគមវិជ្ជាកុម្មុយនិស្ត និងការគំនុំសងសឹករបស់អ្នកនយោបាយខ្មែរ ព្រះពុទ្ធសាសនាបានត្រូវវិនាស ។ បូជនីយដ្ឋាន និងបូជនីយវត្ថុ ដូចជាកុដិ សាលា ព្រះវិហារ ព្រះពុទ្ធរូបជាដើម បានត្រូវខ្មែរក្រហមបំផ្លាញ ។ គម្ពីរក្បួនច្បាប់ព្រះពុទ្ធសាសនា ដូចជាគម្ពីរព្រះត្រៃបិដកជាដើមក៏ត្រូវបំផ្លាញ ។ តាមផែនការរបស់ខ្មែរក្រហម ព្រះសង្ឃប្រទេសកម្ពុជាទាំងមូលត្រូវបង្ខំសឹក បើព្រះសង្ឃណារឹងទទឹងត្រូវកំទេចគឺធ្វើគត់ ។ ចំពោះមន្ត្រីសង្ឃរាជាគណៈ មេគណ អនុគណ ត្រូវកំទេចគឺធ្វើគត់តែម្តង ។ ក្រៅពីសម្តេចសង្ឃនាយកហួត-តាត ដែលត្រូវខ្មែរក្រហមធ្វើគត់ដោយចងព្រះអង្គឲ្យរថយន្តអូសរហូតសុគត ព្រះរាជាគណៈដទៃទៀត ក៏ត្រូវខ្មែរក្រហមធ្វើគត់ជាបន្តបន្ទាប់គ្នា ។

យើងបានទទួលពត៌មានពីយោធាខ្មែរក្រហមម្នាក់ បន្ទាប់ពីអំណាចខ្មែរក្រហមបានត្រូវបញ្ចប់ថា ព្រះតេជព្រះគុណប៉ុណ្យ-សុម្ភាជ មេគណខេត្តបាត់ដំបង និងព្រះតេជព្រះគុណកែវ-សាង វត្តកំផែងជាអនុគណ បានត្រូវខ្មែរក្រហា

មធ្វើគត់យ៉ាងសាហាវបំផុត ។ ទីកន្លែងដែលពួកវាធ្វើគត់ គឺនៅវាលបែកចាន ជិតចំណតអាកាសយានក្រុងបាត់ដំបង ។ ខ្មែរក្រហមបានឲ្យព្រះតេជព្រះគុណ ប៉ុណ្យ-សម្អាជជីករណ្ដៅដោយខ្លួនឯង ។ យោធាខ្មែរក្រហមដែលបានផ្ដល់ ពត៌មាននេះបានពោលថា គេដឹងពត៌មានធ្វើគត់នេះតាមយោធាម្នាក់ដែលរួម ធ្វើគត់បាននិយាយប្រាប់ ។ យោធានោះបានបន្តថា ព្រះតេជព្រះគុណប៉ុណ្យ-សម្អាជបានមានសង្ឃដីការអង្វរខ្មែរក្រហមថា ឲ្យអាត្មាសឹកបានហើយ សូមកុំ ធ្វើគត់ ។ ខ្មែរក្រហមគ្មានឆ្លើយអ្វីឡើយ បង្ខំលោកឲ្យជីករណ្ដៅឲ្យបានឆាប់ ។ ដោយដឹងថាខ្មែរក្រហមនឹងធ្វើគត់មិនទទួលអង្វរ ទើបលោកមានសង្ឃដីកាថា បើធ្វើគត់អាត្មាហើយ សូមយកចីពរគ្របលើផ្នូរឲ្យអាត្មាផង ។ បន្ទាប់ពីជីក រណ្ដៅរួចហើយ យោធាខ្មែរក្រហមបានយកបំពង់សង្កែដែលបានកាប់ទុកជា ស្រេច វាយលោកពីក្រោយត្រង់កញ្ចឹងក រួចរុញទម្លាក់ក្នុងរណ្ដៅ ហើយលុប ដីតែម្ដង មិនដឹងជាលោកវេទនាយ៉ាងណា មុននឹងដាច់ខ្យល់សុគត ។ ព្រះតេ ជព្រះគុណប៉ុណ្យ-សម្អាជ ពេលខ្មែរក្រហមធ្វើគត់នោះ មានឋានៈជាព្រះរាជា គណៈថ្នាក់ទី១ គឺព្រះវិនរត្ន គង់នៅវត្តពោធិវាល ហើយជាមេគណខេត្តបាត់ដំ បងផង ។ ព្រះសង្ឃដីកាថា ពេលអាត្មាសុគត សូមយកចីពរគ្របលើផ្នូរនោះ ទំនងជាលោកចង់ឲ្យពុទ្ធសាសនិកជនខ្មែរមើលឃើញថា ខ្មែរក្រហមបានបំផ្លា ញព្រះពុទ្ធសាសនា ធ្វើគត់ព្រះសង្ឃ ដើម្បីឲ្យពុទ្ធសាសនិកជនខ្មែរក្រោកឡើង ប្រឆាំងនឹងខ្មែរក្រហម ធ្វើឲ្យព្រះពុទ្ធសាសនារស់ឡើងវិញ ។ យោធាខ្មែរក្រហ មអ្នកដឹងរឿងនេះបាននិយាយទៀតថា ចំណែកការធ្វើគត់ព្រះតេជព្រះគុណ កែវ-សាង អនុគណស្រុកសង្កែ មានលក្ខណៈស្រដៀងគ្នានឹងការធ្វើគត់ព្រះតេ ជព្រះគុណប៉ុណ្យ-សម្អាជដែរ ។ ដើម្បីឲ្យដឹងការពិត ពុទ្ធសាសនិកជនខ្មែរអ្នក នៅក្រុងបាត់ដំបង គួរដើររកមើលកន្លែងកប់សពព្រះសង្ឃជាន់ខ្ពស់ទាំងពីរ អង្គនេះ នៅវាលបែកចានក្រុងបាត់ដំបង ។

ព្រះតេជព្រះគុណសេខ-នាង ជាសាស្ត្រាចារ្យបាលីបង្រៀននៅពុទ្ធិកសក-លវិទ្យាល័យព្រះសីហនុរាជ ត្រូវខ្មែរក្រហមធ្វើគត់ក្រោយពេលដែលលោកលា ចាកសិក្ខាបទដោយការបង្ខំពីខ្មែរក្រហមនៅខេត្តព្រៃវែង ខ្លះថានៅខេត្តស្វាយ រៀង ព្រោះលោកធ្វើដំណើរពីវត្តឧណ្ណាលោម ដោយការបណ្ដេញពីខ្មែរក្រហម

ឆ្ពោះទៅស្រុកកំណើតរបស់លោក ។ ការសម្លាប់នោះមានពត៌មានថា ក្រោយពេលដែលលោកបានលាសិក្ខាបទ (សឹក) រួចហើយ ខ្មែរក្រហមបានបង្ខំឲ្យរៀបការជាមួយនារីម្នាក់ ដែលមានអាយុប្រហាក់ប្រហែលគ្នា ។ បន្ទាប់ពីផ្សំផ្គុំហើយ លោកតាសេខ-នាងបាននិយាយប្រាប់នារីដែលជាប្រពន្ធនោះថា ខ្ញុំសុំធ្វើជាបងប្អូន ។ បានសេចក្តីថា លោកតាសេខ-នាងមិនព្រមទទួលរួមដំណេកជាមួយនារីនោះ ក្នុងនាទីជាស្វាមីភរិយាឡើយ គឺនៅជាមួយគ្នាដូចជាបងប្អូន ។ ដំណឹងសម្ងាត់នេះបានឮទៅដល់ខ្មែរក្រហម ពួកវាក៏យកលោកទៅសម្លាប់ដោយចោទថា លោកប្រឆាំងនឹងអង្គការ ។ វិធីសម្លាប់មានលក្ខណៈដូចគ្នានឹងការធ្វើគត់ព្រះតេជព្រះគុណប៉ុណ្ណ្យ-សម្តាជដែរ គឺឲ្យជីករណ្តៅខ្លួនឯង រួចវាយច្រានទម្លាក់ក្នុងរណ្តៅហើយលុបដីកប់ ។ តាមពត៌មាន រណ្តៅដែលកប់លោកតាសេខ-នាងគេរកឃើញហើយ ។ គេបានគាស់ទាំងថង់យាមផង ទំនងជាលោករក្សាទុកថង់យាមនោះ ក្រោយពេលដែលលោកលាចាកសិក្ខាបទ ហើយលោកយកទៅជាមួយនៅពេលដែលគេយកទៅសម្លាប់ ។ អស្ចារ្យណាស់ លោកនៅតែរក្សានូវឧត្តមគតិជាអ្នកបួស មិនព្រមយកភរិយា ទោះបីគេយកទៅសម្លាប់ក៏ដោយ ។ ពុទ្ធបរិស័ទនៅទីនោះបានគាស់យកអដ្ឋិធាតុរបស់លោកហើយបានរៀបចំធ្វើចេតិយដំកល់អដ្ឋិធាតុនោះ ។

វិធីផ្សឹកព្រះសង្ឃឲ្យអស់ពីប្រទេសកម្ពុជា មានការខុសគ្នាតាមទីកន្លែង តាមពត៌មានថា មានកន្លែងខ្លះបង្ខំឲ្យសឹកដោយត្រង់ៗតែម្តង អង្គខ្លះមិនព្រមសឹកត្រូវខ្មែរក្រហមយកទៅធ្វើគត់អស់ជាច្រើនអង្គ កន្លែងខ្លះព្រះសង្ឃត្រូវសឹកខ្លួនឯងដោយស្វ័យប្រវត្តិ ព្រោះជនជាតិខ្មែរទាំងអស់ត្រូវចូលក្នុងសហករណ៍ ហើយគេចែករបបចំណីអាហារតាមកម្លាំងពលកម្ម ចំណែកព្រះសង្ឃមិនបានបំ-ពេញពលកម្មដូចជាគ្រហស្ថ គេមិនចែករបបចំណីអាហារឡើយ ។ ពុទ្ធបរិស័ទមិនអាចប្រគេនចង្ហាន់ ដោយខុសវិន័យខ្មែរក្រហមផង ដោយរបបចំណីអា-ហារតិចតួច មានតែបបររាវៗពីរបីវែក យោងតែខ្លួនឯងមិនរួចផង ។ ទោះបីព្រះសង្ឃខ្លះសុខចិត្តធ្វើការដូចគ្រហស្ថ ឲ្យតែបាននៅភេទជាព្រះសង្ឃ ក៏មិនអាចធ្វើដូច្នេះបានឡើយ ព្រោះផែនការខ្មែរក្រហមត្រូវផ្សឹកព្រះសង្ឃឲ្យអស់ក្នុងបំណាច់ឆ្នាំ១៩៧៥ ។

*ការចងគំនុំសងសឹករបស់អ្នកនយោបាយខ្មែរចំពោះព្រះសង្ឃ ដែលនៅក្រាញជាមួយរបបលោកលន់-នល់ មិនព្រមរត់ចូលរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជារបស់ខ្មែរក្រហមនេះ ជាអំពើព្រៃផ្សៃបំផុត ។ នេះជាឧក្រិដ្ឋកម្មសង្គ្រាម ព្រោះសម្លាប់អ្នកចុះចាញ់ ហើយជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រោះសម្លាប់និងធ្វើគត់អ្នកស្លូតត្រង់ មានព្រះសង្ឃជាដើម ។ គួរពុទ្ធសាសនិកជនខ្មែរទាំងក្នុងប្រទេសនិងក្រៅប្រទេស ធ្វើបុណ្យរំលឹករាល់ឆ្នាំចំពោះព្រះសង្ឃនិងជនជាតិខ្មែរ ដែលត្រូវអ្នកនយោបាយខ្មែរធ្វើគត់ និងសម្លាប់យ៉ាងសាហាវព្រៃផ្សៃនេះ ។៚*

❄ ❄

❄